METHODFINDER



www.MethodFinder.net

# Practitioner's Guide:

## ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

Deutsche Gesellschaft für Technische Zusammenarbeit (GTZ) GmbH

Bundesministerium für wirtschaftliche Zusammenarbeit und Entwicklung

Ministry of Land Management, Urban Planning and Construction

Copyright: Royal Government of Cambodia – GTZ supported: Land Administration and Management Project (LMAP)

Concept and Layout: Nikolaus Schall / Michael Becker

# ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

**បទអត្ថាធិប្បាយសង្ខេប :**



ផែនការអភិវឌ្ឍន៍ថ្នាក់ស្រុក គឺជាឯកសារគោលនយោបាយយុទ្ធសាស្ត្រដែលរៀបរាប់ពីបញ្ហា និងសក្តានុពល នានាដែលមាននៅក្នុង ស្រុកក៏ដូចជាប្រភេទ អភិវឌ្ឍន៍សំរាប់ ពេលអនាគតដែលផ្អែកទៅលើលទ្ធផលនានានៃបង្ហំរូបភាពនិងណែនាំដោយ រូបមន្ត នៃការអភិវឌ្ឍន៍ ពិសេសច្បាស់លាស់មួយចំនួននោះ។ ការធ្វើអត្ថាធិប្បាយអំពីទិសដៅ និងគោលបំណងសំខាន់ៗ និងមធ្យោបាយដែលចាំបាច់នានាសំរាប់សំរេចនូវគោលបំណង និងទិសដៅទាំងនោះត្រូវតែរៀប ចំកសាង ។ ផែនការនោះត្រូវតែឆ្លុះបញ្ចាំងនូវ សុឆន្ទៈនយោបាយ របស់ប្រជាជន ដែលរស់នៅក្នុងស្រុកទាំងមូលរបស់ ថ្នាក់ដឹកនាំស្រុក និងអ្នកមានសិទ្ធអំណាចសំរេចទាំងអស់របស់ស្រុក ។ ផែនការនេះត្រូវសំរបសំរួល និងភ្ជាប់ជាមួយនឹងគោលការណែនាំអភិវឌ្ឍន៍នានា របស់ថ្នាក់ជាតិជា មួយនឹងតំរូវការនិងការចាំបាច់នានារបស់ប្រជាជនមូលដ្ឋាន ។

**ហេតុអ្វី បានជាការរៀបចំកសាងផែនការថ្នាក់ស្រុកជាការចាំបាច់?**

ផែនការថ្នាក់ស្រុកផ្តល់នូវទស្សនវិស័យទូលំទូលាយនៃសក្តានុពលនានាដែលមាននៅក្នុងស្រុក ។ ឯកសារដែល មានចំនួនប្រហែល សាមសិបសន្លឹក រៀបរាប់ជាសង្ខេបអំពីស្ថានភាពបច្ចុប្បន្ននៃកិច្ចការនៅក្នុងស្រុកអំពីបញ្ហាសក្តានុពល និងទិសដៅព្រមទាំងគោលបំណងនានាហើយថាតើគោលបំណង និងទិសដៅទាំងអស់នេះអាចសំរេចបានដ៏ប្រសើរ បំផុតនោះ។ ឧទាហរណ៏ ឯកសារនេះរៀបរាប់ពីគោលគំនិតអភិវឌ្ឍន៏នានា (ដូចជាការណែនាំបង្ហាញពីតំរូវការចាំបាច់ ជាមូលដ្ឋានការកាត់បន្ថយភាពក្រីក្រជាដើម ។ល ។) ដែលបញ្ជាក់ពីយុទ្ធសាស្ត្រ ថាតើទិសដៅអភិវឌ្ឍន៏ជាតិបានទទួល ការកែសំរួល និង ធ្វើអោយមានលក្ខណៈ ជាមូលដ្ឋានទៅតាមលក្ខខណ្ឌមូលដ្ឋានជាក់ស្តែង ។ ការពិតទៅឯកសារនេះគឺ ជាឯកសារនយោបាយដែលមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ដើម្បីធានាអោយបាននូវការអនុមត័ផ្នែកនយោបាយ ដែលចាំបាច់ ក៏ប៉ុន្តែត្រូវមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ផងដែរសំរាប់ជៀសវាងបាននូវការរារាំងដល់សំណើ អភិវឌ្ឍន៏នានានៅពេលអនាគត ។ផែនការថ្នាក់ស្រុកត្រូវគ្រប់ដណ្តប់គ្រប់តំបន់ទាំងអស់នៅក្នុងស្រុកហើយពិនិត្យវិភាគពីទំនាក់ទំនងផ្នែកសេដ្ឋកិច្ចសង្គម និងនយោបាយជាមួយនឹងស្រុកនានា ដែលនៅជាប់ ព្រំប្រទល់។ ផែនការអភិវឌ្ឍន៏ថ្នាក់ទីប្រជុំជន និងភូមិ ប្រសិន បើមាន នឹងផ្តល់នូវធាតុ ផ្សំដ៏មានសារៈប្រយោជន៏ដល់ផែនការអភិវឌ្ឍន៏ថ្នាក់ស្រុក។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

## អ្នកដែលអាចប្រើប្រាស់វិធីសាស្ត្រនេះសំខាន់ជាងគេ

អ្នកកសាងផែនការថ្នាក់ស្រុក តំបន់ និង ថ្នាក់ជាតិ



## គោលបំណងនៃវិធីនេះ



មានតំណាក់កាលរៀបចំផែនការផ្សេងៗគ្នា ហើយដំណាក់កាលនីមួយៗទាមទារដំណើរការកសាងផែនការនិងឯកសារដាច់ដោយឡែកពីគ្នា។

- **នៅកំរិតថ្នាក់ភូមិ :** គួរតែជាចំនុចចាប់ផ្តើមនៃរាល់ការអនុវត្តន៏ក្នុងការកសាងផែនការ ។ សហគមន៏មូលដ្ឋាន ចាំបាច់ត្រូវមានការរៀបចំនិងបំផុសអោយមានសកម្មភាព ពួកគេត្រូវតែជាអ្នកចាប់ផ្តើមនូវដំណើរការកសាងផែនការ របស់ភូមិ ឬសហគមន៏។ សហគមន៏មូលដ្ឋានត្រូវកសាងនូវផលិតផលបីយ៉ាងជាសំខាន់គឺទស្សនវិស័យ ការកំណត់ផែនការអភិវឌ្ឍន៏ជាអាទិភាពរបស់សហគមន៏ និង ការកំណត់គំរោងជាក់ស្តែង ឬ ផែនការសកម្មភាពគំរោងនានារបស់ សហគមន៏។
- **កំរិតនៃតំបនអភិវឌ្ឍន៏១ដូចជាកំរិតថ្នាក់អនុស្រុកជាដើមៈ** តំបន់ អភិវឌ្ឍន៏ ចាំបាច់ត្រូវមានការសំរេចដែល តំបន់ទាំងនេះអាចខុសពីព្រំប្រទល់រដ្ឋបាល គឺតំបន់ អភិវឌ្ឍន៏ទាំងនេះជាតំណាងអោយឱកាសអភិវឌ្ឍន៏ ។ ទស្សនវិស័យ យូរអង្វែង និងយុទ្ធ សាស្ត្រ អភិវឌ្ឍន៏ទូទៅគួរតែមានការកសាងសំរាប់តំបន់អភិវឌ្ឍន៏និមួយៗ ។
- **កំរិតថ្នាក់ស្រុកៈ** វាផ្តល់នូវរចនាសម្ព័ន្ធសំរាប់ការសំរេចទៅ លើការណែនាំ ពីការរៀបចំផែនការវិនិយោគ សំរាប់ រយៈពេលលើសពី ១០-១៥ឆ្នាំហើយ ប្រើប្រាស់ ជាមូលដ្ឋានសំរាប់ផែនការអភិវឌ្ឍន៏ថ្នាក់ស្រុកក្នុងកំរិតរយៈពេលមធ្យម និង ប្រចាំឆ្នាំ ។
- **កំរិតថ្នាក់ជាតិៈ** ផែនការអភិវឌ្ឍន៏នៅកំរិតថ្នាក់ជាតិ អាចកសាង ឡើងដោយ ការរួមបញ្ចូលនូវផែនការយុទ្ធ សាស្ត្ររយៈពេលវែង ដែលជាទូទៅរួម បញ្ចូលនូវ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ផែនការវិនិយោគតាមវិស័យនីមួយៗ ។ល ។រចនាសម្ព័ន្ធនៃ

ការ ចំណាយរយៈពេលមធ្យមគឺជាផែនការរយៈពេលមធ្យមនេះឯង ។ផែនការទូទៅប្រចាំឆ្នាំគឺជា តំរូវការចាំបាច់ត្រូវមាន នៅកំរិតថ្នាក់ជាតិដើម្បីបែងចែកនូវការចំណាយប្រចាំឆ្នាំ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

## គោលបំណងនៃវិធីនេះ



**រូបភាពទី១ : កំរិតនៃការកសាងផែនការទូទៅ និងឯកសារនៃលទ្ធផលនៃការកសាងផែនការ**

| រយៈពេលកំរិត / នៃការកសាងផែនការ | កំរិតថ្នាក់ភូមិ | តំបន់អភិវឌ្ឍន៍ឬកំរិតថ្នាក់អនុតំបន់ | កំរិតថ្នាក់ស្រុក | កំរិតថ្នាក់ជាតិ |
|---|---|---|---|---|
| រយៈពេលវែង (១៥ ដល់ ២០ ឆ្នាំ) | ទស្សនវិស័យ | ទស្សនវិស័យ | ផែនការយុទ្ធសាស្ត្ររយៈពេលវែង | ផែនការអភិវឌ្ឍន៍ជាតិ |
| រយៈពេលមធ្យម (បីឆ្នាំ) | ការកំណត់ផែនការអភិវឌ្ឍន៍អាទិភាពរបស់សហគមន៍ | យុទ្ធសាស្ត្រនៃការកំណត់តំបន់អភិវឌ្ឍន៍ | ផែនការរយៈពេលមធ្យម | -កម្មវិធីកាត់បន្ថយភាពក្រីក្រ<br>-រចនាសម្ព័ន្ធនៃការចំណាយរយៈពេល មធ្យម |
| រយៈពេលខ្លី (មួយឆ្នាំ) | ផែនការសកម្មភាពរបស់សហគមន៍ | គំរោងអន្តរសហគមន៍ជាអទិភាព | ផែនការសកម្មភាពប្រចាំឆ្នាំ | ផែនការអភិឌ្ឍន៍ប្រចាំឆ្នាំ |

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

## ផលប្រយោជន៍

- ការកសាងផែនការយុទ្ធសាស្ត្រផ្តល់នូវទស្សនវិស័យសំរាប់រយៈពេលវែងវា គឺជាការងារ ដែលលើសពីការសរុបនូវផែនការសកម្មភាពរបស់គ្រប់ភូមិទាំងអស់នោះទៅទៀត ។
- ផែនការយុទ្ធសាស្ត្រ សង្កត់ធ្ងន់ទៅលើសក្តានុពលនៃការអភិវឌ្ឍន៍ ហើយថា តើការងារ ទាំងនេះអាចដាក់បញ្ចូលទៅក្នុងផែនការរយៈពេលវែងយ៉ាងដូចម្តេច ។
- ផែនការនោះ ផ្តល់នូវការខិតខំទាំងស្រុងក្នុងការប្រមើលមើលនូវអនាគតរបស់ស្រុក ឬ តំបន់ដែលតាមរយៈនេះ
  គោលបំណងដ៏ទូលំទូលាយតែមានភាពប្រាកដនិយមត្រូវបានកំណត់ ។
- ផែនការយុទ្ធសាស្ត្រ ផ្តល់នូវមូលដ្ឋានដល់អ្នកនយោបាយ និងសហគមន៍ដើម្បីពិភាក្សា ថាតើពួកគេអាចប្រើប្រាស់នូវសក្តានុពលអភិវឌ្ឍន៍ដែលមានស្រាប់យ៉ាង ដូចម្តេច អោយមានប្រសិទ្ធភាពខ្ពស់បំផុតនោះ ។
- ផែនការនេះទាមទារអោយមានការឯកភាពមួយរវាងអ្នកនយោបាយសហគមន៍ និង រដ្ឋបាល ។ផែនការនេះណែនាំទាំងការវិនិយោគរយៈពេលមធ្យមនិងរយៈពេលវែង ធ្វើយ៉ាង ណាអោយសំរេចបាន នូវគោលបំណងរយៈពេលវែង ។

## ដែនកំណត់

- ការសម្របសម្រួល រវាងសេចក្តីប្រាថ្នាផ្នែកនយោបាយ តំរូវការនិងការចាំបាច់របស់សហគមន៍ និងផលប្រយោជន៍របស់វិស័យឯកជនអាចនឹងមិនត្រូវបានផ្សារភ្ជាប់គ្នានៅក្នុងរយៈពេលវែង ។
- ទស្សនវិស័យរយៈពេលវែងអាចមានលក្ខណៈពិបាកនិង សំរេចការ ហើយអាច ធ្វើឱ្យ អ្នកធ្វើការ សំរេចមានការខ្លាចរអាលើការសំរេចភ្លាមៗ ។
- ការចូលរួមយ៉ាងសកម្មពីសហគមន៍ទាំងអស់គឺជាការលំបាកធ្វើហើយមានក៏រិតខ្ពស់ ។
- ការចូលរួមរបស់សហគមន៍អាចបង្កអោយកើតមានសេចក្តីសង្ឃឹម ដែលសេចក្តីសង្ឃឹម ទាំងនេះមួយចំនួនអាច សំរេចបានតែនៅក្នុងរយៈពេលវែងប៉ុណ្ណោះ ។
- សហគមន៍អាចចង់បាននូវផលប្រយោជន៍រយៈពេលខ្លីភ្លាមៗ
  ជាងផលប្រយោជន៍រយៈពេលវែងដែលករណីនេះ អាចជះ
  ឥទ្ធិពលលើការជ្រើសរើសអំពីយុទ្ធសាស្ត្ររបស់ស្រុក ។
- ផែនការយុទ្ធសាស្ត្រអាចក្លាយជាការសិក្សាស្រាវជ្រាវហើយវាអាចមិនត្រូវប្រើប្រាស់ជាញឹក ញាប់ជាការដាក់ បញ្ចូលទៅក្នុងផែនការរយៈពេលមធ្យម និងរយៈពេលវែង ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

## គោលការណ៍និងដំណើរការទូទៅ



ដើម្បីបំពេញផែនការសំរាប់ស្រុកបានទាមទារអោយមានជំហ៊ាននៃកាលវិភាគជាច្រើនដែលត្រូវបំពេញដូចជា :

- ការវិភាគស្ថិតិវន្ត (ស្តាទិច)
- ការវិភាគឌីណាមិុច
- ការអភិវឌ្ឍន៏នៃតំបន់អភិវឌ្ឍន៏ផ្ទៃកូរបវ័ន្ត
- ការកសាងនូវរូបភាពអភិវឌ្ឍន៏ដែលអាចមានលក្ខណ:សមស្របបំផុតសំរាប់ស្រុក
- ការកសាងនូវទស្សនវិស័យ សំរាប់តំបន់អភិវឌ្ឍន៏
- ការកសាងនូវយុទ្ធសាស្ត្រអភិវឌ្ឍន៏សំរាប់ស្រុក និងយុទ្ធសាស្ត្រតាមវិស័យ
- ការសំរបសំរួលនូវតំរូវការធនធាន ប្រភពថវិការ និងការរៀបចំរចនាសម្ព័ន្ធ

**ការវិភាគស្តាទិច:**ជំហ៊ានដំបូងនៃដំណើរការត្រូវមានការវិភាគស្តាទិច ។ នៅក្នុងរយ:ពេលនៃការ វិភាគ ស្តាទិចក្រុមការងាររៀប ចំកសាងផែនការពិនិត្យ ទៅលើពត៌មានដែលទទួលបានជាប្រភេទ ទិន្នន័យមានស្រាប់ ១ ដូចជាទទួលបានពីរបាយការណ៏ ដែលមានស្រាប់ការសិក្សា នានារបាយការណ៏ពិនិត្យ ពីភាពជាក់ស្តែងក៏ដូចជាពីការទទួលបានពត៌មានដែលមាននៅក្នុង ផែនការនានារបស់សហគមន៏ដែរ )។ ប្រសិនបើពត៌មានដែលមានស្រាប់គ្មានលក្ខណ: គ្រប់គ្រាន់ទេ១ទាំងផ្នែកគុណភាព និងបរិមាណ) នោះទើបអាចមានការប្រមូលនូវទិន្នន័បឋម។ ប៉ុន្តែកិច្ចការនេះ ទាមទារនូវធនធានធំសំបើមណាស់ ។

**ការវិភាគឌីណាមិច:**នៅក្នុងរយ:ពេលនៃការវិភាគឌីណាមុិច ពត៌មានដែលទទួលបានលើការវិភាគ ស្តាទិចត្រូវបានយកមកវិភាគបន្ត យកមកធ្វើការទស្សទាយ ហើយរូបភាពនានាត្រូវបានរៀបចំកសាងឡើង ។ ឧទាហរណ៏ ការទស្សទាយពីប្រជាជនធ្វើ ឡើងផ្អែកទៅលើការទស្សទាយ ពីកំណើនប្រជាជនផ្សេងៗគ្នា ។ ភារកិច្ចមូលដ្ឋានគឺ សំរេចថាតេគោលគំនិតនៃការ អភិវឌ្ឍន៏នាពេលអនាគតអាចមានរូបរាងដូចម្តេច ។ ឧទាហរណ៏ ប្រសិនបើប្រជាជននៅតែបន្តកើនឡើងដោយគ្មាន ការត្រួតពិនិត្យ ឬអត្រាកំណើនអាចធ្លាក់ចុះជាគំហ៊ុកនោះនឹងមានការបកស្រាយដ៏សំខាន់សំរាប់ការអភិវឌ្ឍន៏ទាំងថ្នាក់ មូលដ្ឋាន និងថ្នាក់ស្រុក ។រូបភាពដ៏ល្អឥតខ្ចោះ ឬរូបភាពដែលល្អនៃការអភិវឌ្ឍន៏ ត្រូវបានជ្រើសរើស ហើយប្រើប្រាស់នៅ ក្នុងការងាររៀបចំកសាងផែនការជាបន្ទាប់មកទៀត។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

## គោលការណ៍និងដំណើរការទូទៅ



**ការកំណត់តំបន់រូបវន្ត:**នៅក្នុងករណីដែលស្រុកនីមួយៗមានលក្ខណៈពិសេសផ្សេងៗគ្នា នោះភាពខុសគ្នានៅក្នុងស្រុកនីមួយៗក៏កើត មានឡើងដែរ ។ ផ្នែកខុសគ្នារបស់ស្រុកមានធនធាន និង សក្តានុពលក៏ខុសគ្នាដែរ ។ជាលទ្ធផលដែលបាន អនុវត្តន៍នៅក្នុងជំហ៊ានដំបូងៗនោះរូបភាព រូបវ័ន្តពិសេសៗរបស់ទីតាំងនីមួយៗត្រូវបានកំណត់ហើយតំបន់អភវឌ្ឍន៏ថ្មីៗ ក៏ត្រូវបានកំណត់ផងដែរ ។ តំបន់អភិវឌ្ឍន៏តំណាងអោយទីតាំងរូបវ័ន្តជាមួយនឹងរូបភាពនៃការអភិវឌ្ឍន៏ពិសេសប្រហាក់ប្រហែល គ្នាដែរ ( ដូចជាសក្តានុពលធនធាន ។ល ។ )

**ការបង្កើតជាទស្សនះវិស័យ:** សំរាប់តំបន់អភិវឌ្ឍន៏នីមួយៗត្រូវមានទស្សនះវិស័យ ។ ដោយការប្រើប្រាស់លទ្ធផលនៃការវិភាគឪណាម៉ិច គំនិតឆ្នៃប្រឌិតដែលបានលើកឡើងរបស់ប្រជាជន និងក្រុមអ្នករៀបចំកសាងផែនការមានតួនាទីដ៏សំខាន់នៅក្នុងការ កសាងទស្សនវិស័យនានា ។ ទស្សនវិស័យ កំណត់ថាតើគ្រប់ភាគីទាំងអស់យល់ឃើញពីអនាគតរបស់ស្រុកហើយ ទស្សនវិស័យទាំងនោះតំណាងអោយទស្សនះរយះពេលវែង(ឧទាហរណ៍ រយះពេល១៥ ឆ្នាំដល់២៥ឆ្នាំ)នៃការអនុវត្តន៏ របស់ស្រុក ។ទស្សនវិស័យមានលក្ខណះទូទៅ និងមានលក្ខណះ ជាបេសកម្មដែលឃ្លាតឆ្ងាយពីផែនការលំអិតរយះពេល មធ្យម និង វែង (ដូចជាបញ្ជីរាយឈ្មោះ ទំនិញលំអិត ) ។

**ការរៀបចំជាយុទ្ធសាស្ត្រ :** ស្រដៀងទៅនឹងករណីពិតដែលមធ្យោបាយធ្វើដំណើរមានច្រើនបែបដែរ ( ដូចជាតាម រថយន្តកង់ យន្តហោះ ជាដើម) ដែលអាចប្រើប្រាស់ដើម្បីទៅដល់គោលដៅណាមួយនោះ វាក៏មានយុទ្ធសាស្ត្រខុសៗគ្នាដែរ សំរាប់ប្រើប្រាស់ ដើម្បីសំរេចបាននូវទស្សនវិស័យ ។ ភាពខុសៗគ្នានៅក្នុងយុទ្ធសាស្ត្រជាញឹកញាប់ឆ្លុះបញ្ចាំងអំពីទស្សនវិជ្ជាខុសៗគ្នាដែរ (ដូចជាផ្អែកលើកំណើនឬការយល់ពីបរិស្ថាន ។ល ។) យុទ្ធសាស្ត្រអភិវឌ្ឍន៏ គួរតែផ្អែកទៅលើទ្រឹស្តី និងគោលគំនិត អភិវឌ្ឍន៏ ។ ឧទាហរណ៏អំពីទ្រឹស្តីអភិវឌ្ឍន៏រួមមានការជ្រើសរើសតំបន់បិទជិត ការរីកលូតលាស់ដែលផ្អែកទៅលើការ នាំចេញ ។ល ។ក្រៅអំពី ទ្រឹស្តីអភិវឌ្ឍន៏ទស្សនះទាន ដែលមាន លក្ខណះដាច់ដោយដុំដ៏ទៃទៀត ក៏អាចមានតួនាទីសំខាន់ នៅក្នុងការកសាងយុទ្ធសាស្ត្រដែរ រួមមាន ការបន្ថយតំលៃឯកជនភាវូបនីយកម្ម ហិរញ្ញវត្ថុភាវូបនិយកម្ម ដៃគូរវាង ឯកជន និងសាធារណះ ។ ច្បាប់ជាតិជាមូលដ្ឋាននិងគោលនយោបាយនានាក៏ជាកត្តាណែនាំដល់យុទ្ធសាស្ត្រផងដែរ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

## គោលការណ៍និងដំណើរការទូទៅ

**រូបភាពទី ២ : ពីទស្សនវិស័យរបស់សហគមន៍ឆ្ពោះទៅផែនការយុទ្ធសាស្ត្រស្រុក**




Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការយុទ្ធសាស្ត្រថ្នាក់ស្រុក

## គោលការណ៍និងដំណើរការទូទៅ



**យុទ្ធសាស្ត្រនានាតាមវិស័យនិមួយៗ:** នៅពេលកសាងបញ្ចប់នូវទស្សនវិស័យ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍ ទូទៅរួចហើយ វិស័យនិមួយៗត្រូវតែកសាង យុទ្ធសាស្ត្រនិមួយៗរៀងៗខ្លួន ។ឧទាហរណ៍ ប្រសិន បើមានការយល់ព្រមថា យុទ្ធសាស្ត្រជាដៃគូរវាងឯកជន និងសា ធារណៈត្រូវតែជ្រើសរើសយកនោះ យុទ្ធសាស្ត្ររបស់វិស័យនិមួយៗត្រូវតែកំណត់នូវអ្វីដែលយុទ្ធសាស្ត្រនេះមានសំរាប់វិស័យកសិកម្ម សុខាភិបាល ។ល។ លទ្ធផលមួយដែលអាចយកទៅអនុវត្តគឺ មិនផ្តល់សេវាកម្ម ដោយឥតយកថ្លៃនៅក្នុង ទីតាំងនានាដែលវិស័យឯកជន អាចផ្តល់ជូនបានគ្រប់គ្រាន់ហើយនៅលើទីតាំងដែលសហគមន៍មានជីវភាពល្អសមរម្យ អាចនឹងចេញថ្លៃសេវាកម្មទាំងនោះបានដោយខ្លួនឯង ។ដូចគ្នានេះដែរ វិស័យសុខាភិបាលគួរតែបង្វែរទិសដៅ បុគ្គលិករបស់ខ្លួនទៅទីតាំងណា ដែលគ្មានសេវាកម្មឯកជនវិញ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## References and Sources Used



Jenssen, B.;(ed), **Planning as a Dialogue,** District Development Planning and Management in Developing Countries, SPRING Research Series Nr. 2, Dortmund, 1992

Jenssen, B.; **Towards a Quantification of Agglomeration Disadvantages in Metroploitan Areas of Developing Countries**, University of Dortmund, IRPUD, 1984

Rondinelli, Dennis, A.: **Applied Methods of Regional Planning: The Urban Functions in Rural Development Approach**, Clark University: Rural Marketing Centers Working Group (USAID), 1983a

Thimm, Hr.R., Green, D.A.G., Leupolt, M. (Eds); P**lannning and Operating Rural Centres in Developing Countries,** Studien zur Ländlichen Entwicklung. No. 18, 1986

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)